ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤០២ ប្រ.ក កសក

# ប្រកាស

## ស្តីពី

## គំរូបញ្ជិកា វិញ្ញាបនបត្រ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញា យថាប្រភេទកៅស៊ូកម្ពុជា និង លិខិតទទួលស្គាល់ជាផ្លូវការ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នយើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ. បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ. បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- បានឃើញប្រកាសលេខ០៨៦ប្រក.កសក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៤ ស្តីពីការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- តាមសំណើរបស់នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ⁄

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh. Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់នូវគំរូបញ្ជិកា វិញ្ញាបនបត្រ លិខិតអនុញ្ញាតពាក់ព័ន្ធក្នុងការបញ្ជាក់គុណភាពកៅស៊ូកម្ពុជា ក្នុងគោលបំណងធានានូវឯកសណ្ឋានភាពនៃស្តង់ដារគុណភាពយថាប្រភេទកៅស៊ូកម្ពុជា ដើម្បីផ្តល់នូវជំនឿទុកចិត្តចំពោះទីផ្សារជាតិ និង អន្តរជាតិក្នុងការធ្វើពាណិជ្ជកម្មកៅស៊ូដែលមានប្រភពដើមផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អនុញ្ញាតឱ្យវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាប្រើប្រាស់គំរូបញ្ជិកា វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតពាក់ព័ន្ធក្នុងការបញ្ជាក់គុណភាពកៅស៊ូកម្ពុជា ចំនួន ០៦ (ប្រាំមួយ) មុខ ភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះដូចខាងក្រោម ÷

១-វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

២-វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ចេញដោយមន្ទីរពិសោធន៍មូលដ្ឋាន ។

៣-បញ្ជិការោងចក្រកែច្នៃកៅស៊ូ ។

៤-បញ្ជិកាមន្ទីរពិសោធន៍មូលដ្ឋាន ។

៥-លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ។

៦-លិខិតទទួលស្គាល់ផ្លូវការមន្ទីរពិសោធន៍មូលដ្ឋាន ។

**ប្រការ ៣ :** គំរូបញ្ជិកា វិញ្ញាបនបត្រ លិខិតអនុញ្ញាត ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ អាចធ្វើការកែសម្រួល ឬ បង្កើតគំរូថ្មី ស្របតាមភាពចាំបាច់ក្នុងការអភិវឌ្ឍវិស័យកៅស៊ូជាតិ ។

**ប្រការ ៤:** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកនៃក្រសួង អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ នាយកខុទ្ទកាល័យ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**ចន់ សារុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ